**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
======

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
======

# ស្ថានទូតកម្ពុជានៅម៉ាឡេស៊ី អន្តរាគមជួយពលការិនីខ្មែរ៤នាក់

------------

ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេស**ម៉ាឡេស៊ី** បានអន្តរាគមដោះស្រាយបញ្ហា និងរៀបចំមាតុភូមិនិវត្តន៍របស់ពលការិនីខ្មែរចំនួន**៤នាក់** ដូចខាងក្រោម៖

(១) ពលការិនី **ន.ស.ខ** អាយុ៣៣ឆ្នាំ មកពីស្រុកមេមត់ ខេត្តកំពង់ចាម បានទៅម៉ាឡេស៊ី ធ្វើការជាអ្នកបោសសំអាត កាលពីថ្ងៃទី ០៨ ខែ មករា ឆ្នាំ២០១៦ តាមរយៈក្រុមហ៊ុនមួយនៅកម្ពុជា។ ដោយសារនិយោជកមិនបើកប្រាក់ខែឲ្យ ពលការិនីបានទៅស្ថានទូត នៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៧ ដើម្បីស្នើស្ថានទូតជួយទាមទារប្រាក់ខែដែលនៅសល់ពីនិយោជក និងជួយនាងឲ្យបានវិលត្រឡប់មកកម្ពុជាវិញ។

ក្រោមកិច្ចអន្តរាគមន៍របស់ស្ថានទូត និយោជករបស់ពលការិនី បានទៅស្ថានទូតនៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៧ ហើយបានប្រគល់ប្រាក់ខែដែលនៅសល់ និងលិខិតឆ្លងដែន ជូននាងវិញ។

(២) ពលការិនី **អ.ម.ឌ** អាយុ១៨ឆ្នាំ មកពីខេត្តព្រៃវែង

(៣) ពលការិនី **ម.ស.ជ** អាយុ២១ឆ្នាំ មកពីស្រុកតំបែរ ខេត្តកំពង់ចាម

ពលការិនីទាំង២នាក់ បានទៅម៉ាឡេស៊ីដោយខុសច្បាប់ ធ្វើការជាអ្នកបោសសំអាត កាលពីខែកក្កដា ឆ្នាំ ២០១៦ តាមរយៈក្រុមហ៊ុនមួយនៅកម្ពុជា។ ដោយចង់ត្រឡប់មកកម្ពុជាវិញ អ្នកទាំងពីរបានស្នើសុំកិច្ចសម្របសម្រួលពីស្ថានទូត នៅថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៧។

(៤) ពលការិនី **ឃ.ខ** អាយុ៣១ឆ្នាំ មកពីស្រុកសណ្តាន់ ខេត្តកំពង់ធំ បានទៅម៉ាឡេស៊ីដោយខុសច្បាប់ ធ្វើការជាអ្នកបោសសំអាត កាលពីខែកុម្ភៈ ឆ្នាំ២០១៧ តាមរយៈក្រុមហ៊ុនមួយនៅកម្ពុជា។ ដោយចង់ត្រឡប់ទៅកម្ពុជាវិញ ពលការិនីបានទៅស្ថានទូត នៅថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៧។

ស្ថានទូតបានសម្របសម្រួលជាមួយការិយាល័យអន្តោប្រវេសន៍ម៉ាឡេស៊ី ហើយពលការិនីទាំង**៤**នាក់ខាងលើ នឹងមកដល់អាកាសយានដ្ឋានអន្តរជាតិ**ភ្នំពេញ** នៅថ្ងៃទី **២១** ខែ **ឧសភា** ឆ្នាំ **២០១៧** វេលាម៉ោង**១០:០០**នាទីព្រឹក តាមជើងយន្តហោះ **MH754** ។

ក្នុងអំឡុងពេលរង់ចាំត្រឡប់មកកម្ពុជាវិញ ស្ថានទូតបានផ្តល់កន្លែងស្នាក់នៅ និងអាហារបរិភោគជូនពលការិនីទាំង៤នាក់ផងដែរ៕

ភ្នំពេញ, ថ្ងៃទី១៩ ខែ ឧសភា ឆ្នាំ ២០១៧

**ជុំ សុន្ទរី**
**អ្នកនាំពាក្យ**
ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ